


# ហត់ស្ប៉ត WIFI ឥតគិតថ្លៃ នៅTACOMA

**98403, 98405, 98406, 98407, 98465**

ហត់ស្ប៉ត Xfinity WiFi មានផ្តល់ជូនឥតគិតថ្លៃសម្រាប់អ្នកដែលត្រូវការប្រើប្រាស់ក្នុងអំឡុងពេលមានការរាតត្បាតនៃជំងឺ COVID-19 រួមទាំងអតិថិជនផ្សេងក្រៅពីអតិថិជន Xfinity។ ចូលមើលទីតាំងហត់ស្ប៉តដែលមាននៅលើផែនទីខាងលើជាមួយឧបករណ៍អេឡិចត្រូនិក របស់អ្នក ដើម្បីចូលប្រើអ៊ីនធឺណិតដោយឥតគិតថ្លៃ។ អនុវត្តតាមជំហាននៅខាងក្រោយ ដើម្បីភ្ជាប់អ៊ីនធឺណិត។

GRADUATE! TACOMA

## សិទ្ធិប្រើប្រាស់សម្រាប់សិស្ស និងបច្ចេកវិទ្យា

អង្គការមូលនិធិសម្រាប់សិស្ស Tacoma បានសហការជាមួយ Rainier Connect និងសាលារដ្ឋ Tacoma ដើម្បីភ្ជាប់ទំនាក់ទំនងសិស្សកាន់តែច្រើនឡើងទៅនឹងឧបករណ៍ និងអ៊ីនធឺណិតចំពេលដែលបិទសាលារៀនដោយសារវីរុសករ៉ូណា។ យើងមានកុំព្យូទ័រយួរដៃមានកំណត់សម្រាប់ជូនឥតគិតថ្លៃ និងការជាវអ៊ីន ធឺណិតពេញមួយឆ្នាំសម្រាប់ក្រុមគ្រួសារដែលមិនមានអ៊ីនធឺណិតតនៅផ្ទះ និង/ឬកុំព្យូទ័រ។ ដាក់ពាក្យតាមអនឡាញលើគេហទំព័រ bit.ly/gttechform ឬទូរស័ព្ទទៅលេខ (253) 327-1448។

# វិធីចូល

# XFINITY WIFI ឥតគិតថ្លៃ

1

នៅលើដែសថបរបស់អ្នក សូមរកមើលរូបតំណាងសញ្ញា Wifi ដែលស្ថិតនៅផ្នែកខាងក្រោម ឬខាងលើនៃអេក្រង់កុំព្យូទ័ររបស់អ្នក។ ចុចលើវា ដើម្បីបង្ហាញបញ្ជីបណ្តាញដែលមាន។






រកមើលបណ្តាញដែលមានឈ្មោះថា "xfinitywifi" ហើយបន្ទាប់មកចុចភ្ជាប់។

2

3

បើអ្នកមិនត្រូវបានផ្តល់ជម្រើសក្នុងការភ្ជាប់ សូមសាកល្បងបើកកម្មវិធីរុករកអ៊ីនធឺណិតរបស់អ្នកដើម្បីបើកផ្ទាំងវិនដូដែលសួរថាតើអ្នកចង់តភ្ជាប់ដែរឬទេ។




អតិថិជនអ៊ីនធឺណិត Xfinity អាចចូលដោយប្រើ Xfinity ID និងពាក្យសម្ងាត់របស់ពួកគេដើម្បីភ្ជាប់ដោយស្វ័យប្រវត្តិទៅហាត់ស្ប៉ត Xfinity WiFi នៅពេលខាងមុខ។
អតិថិជនអ៊ីនធឺណិតផ្សេងទៀតក្រៅពីអតិថិជន Xfinity អាចភ្ជាប់បានដោយចុចប៊ូតុង "ព្រមទទួល" និង "តភ្ជាប់"។ អតិថិជនផ្សេងទៀតក្រៅពីអតិថិជន Xfinity អាចបន្តរយៈពេលប្រើប្រាស់របស់ពួកគេ
រាល់ 12 ម៉ោងម្តង។